ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកក្កដា ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងខែកក្កដា ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុទទួលឥទ្ធិពលពីជ្រលងសម្ពាធទាប និងទទួលរងនូវព្យុះរ៉ាម៉ាសាន់ ធ្វើឲ្យផ្ទៃមេឃមានពពកច្រើន ព្រមទាំងមានភ្លៀងធ្លាក់ជាមធ្យមនិងតិចតួចនៅតាមតំបន់នៃរាជធានី ខេត្ត ក្រុង ស្រុក រួមជាមួយនឹងខ្យល់សម្ពាធទាបបក់ពីទិសនិរតី។ ទោះបីជាបរិមាណទឹកភ្លៀងអំណោយផលមិនទាន់រាយប៉ាយល្អប្រសើរក៏ដោយ ក៏ប្រជាកសិករទូទាំងប្រទេស បានខិតខំជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការងារបង្កបង្កើនផលស្រូវរដូវវស្សា ដោយបាននិងកំពុងមមាញឹកក្នុងការរៀបចំភ្ជួររាស់ សាប ព្រោះ ដក ស្ទូង ដោយសម្រេចលទ្ធផលបានប្រមាណ៦២,១៣ភាគរយ នៃផែនការដាំដុះចំនួន២.៤១១.២០៧ហិកតា។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន១.៩៦៣.៦២៨ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៣៧១.៩២៧ហិកតា ស្មើនឹង ១៨,៩៤% និងគ្រឿងយន្តចំនួន១.៥៩១.៧០១ហិកតា ស្មើនឹង៨១,០៦%) តិចជាងឆ្នាំមុនចំនួន១៨៥.៦៨៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន១៦៤.៧១៤ហិកតា

-ផ្ទៃដីសាបសរុបចំនួន៨៦.២០១ហិកតា តិចជាងឆ្នាំមុនចំនួន៤៤.៦៦៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៧១.៩៧០ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន១.៤៩៨.០៤២ហិកតា ស្មើនឹង៦២,១៣ភាគរយនៃផែនការ២.៤១១.២០៧ហិកតា លើសឆ្នាំមុនចំនួន១៦៨.១១៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១២៤.៣០៩ហិកតាក្នុងនោះ៖

- ស្រូវស្រាលចំនួន៤៣៣.៦១០ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន២១៤.៧៩៤ហិកតា) លើសឆ្នាំមុនចំនួន៣៣.៧១៤ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៤០.៧៩៥ហិកតា
- ស្រូវកណ្តាលចំនួន៦២៣.៣៨៣ហិកតា លើសឆ្នាំមុនចំនួន១១៩.៦៣២ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៩៤.៩៣៧ហិកតា
- ស្រូវធ្ងន់ចំនួន៣៤៧.១៩២ហិកតា លើសឆ្នាំមុនចំនួន៣១.២៥៤ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន២៣.៥៣២ហិកតា
- ស្រូវចម្ការចំនួន៤២.២៥៤ហិកតា តិចជាងឆ្នាំមុនចំនួន២.៧៨៤ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣.៦៣៩ហិកតា
- ស្រូវឡើងទឹកចំនួន៥១.៦០៣ហិកតា តិចជាងឆ្នាំមុនចំនួន១៣.៧០៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣១.៣១៦ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

### ១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៦២៥.៨៧០ហិកតា ស្មើនឹង១១៨,៥៣% នៃផែនការចំនួន៥២៨.០១៨ហិកតា លើសឆ្នាំមុនចំនួន៥២.៦១៣ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន៨៨.៧២២ហិកតា (ក្នុងនោះពោតក្រហម៧០.៦៦០ហិកតា) តិចជាងឆ្នាំមុន៤០.៨៩៧ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន៤៧៦.០០៣ហិកតា លើសឆ្នាំមុន១០២.៤៦០ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន៣.០០១ហិកតា តិចជាងឆ្នាំមុន៦៦៧ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២៣.៥៨៣ហិកតា តិចជាងឆ្នាំមុន៥២៧ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន៣៤.៥៦១ហិកតា តិចជាងឆ្នាំមុន៧.៧៥៦ហិកតា ។

### ១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន៩២.៥៩១ហិកតា ស្មើនឹង៥៨,៩៧% នៃផែនការ១៥៧.០០៧ហិកតា តិចជាងឆ្នាំមុន២.៥៥៥ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន១៣.៥៩៣ហិកតា តិចជាងឆ្នាំមុន១.៣៩៥ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន២៨.៥០៨ហិកតា តិចជាងឆ្នាំមុន៧៣២ហិកតា

-ផ្ទៃដីល្ងចំនួន៣៥.៤៦៦ហិកតា លើសឆ្នាំមុន១.៩៨៧ហិកតា

-ផ្ទៃដីអំពៅចំនួន១៤.៧៧២ហិកតា តិចជាងឆ្នាំមុន២.៣៦៥ហិកតា

-ផ្ទៃដីក្រចៅចំនួន១៧៣ហិកតា តិចជាងឆ្នាំមុនចំនួន៤៣ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន៧៩ហិកតា តិចជាងឆ្នាំមុន៣ហិកតា។

### ១.៤ ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៤

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានលើផ្ទៃដីសរុបចំនួន៣៧.១៦៨ហិកតា លើសឆ្នាំមុន១.៥៥៧ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន១៤៤.១៧៧តោន លើសឆ្នាំមុន៣.៨៩៨តោន និងទិន្នផលជាមធ្យមចំនួន៣,៨៧៩តោនក្នុងមួយហិកតា លើសឆ្នាំមុន៦០គីឡូក្រាមក្នុងមួយហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៨៤,៣១ | ២៦២,២០ | ១០០,០០ |
| | **សរុប I** | **៤០៦,៦០** | **៣៨៤,៣១** | **២៦២,២០** | **១០០,០០** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,០០ | ៥.៣២៧,០៥ | ៨.៤៤៩,២៩ | ៣.៣៥៧,៤៨ |
| ២ | ក្រុមហ៊ុន ស៊ីហ្សាប់បើលីមីធីត (រតនគិរី) | ៣៦៧,៣៥ | ១.៦២៥,៩០ | ៤៣៤,៨២ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ៨៨៥,០១ | ៤៤៩,៨២ | ៣៨៤,៤០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៣៨៤,៩៧ | ៣.០៥៨,២៧ | ២.៣៨៦,២៤ | ១.៧២៥,៨០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.២៥៩,០៨ | ១.៩៧១,៩៦ | ១.០៨៨,១៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្សីវសេស (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ៩៤៤,៦៣ | ៧៤៦,៨០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១១៨,៣២ | ៨០០,៥៣ | ៥១០,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៣៩,២១ | ៦៨២,៨០ | ៣៨០,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |

| | | | | | |
|---|---|---|---|---|---|
| ១០ | ក្រុមហ៊ុនគ្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.០៧៧,៩២ | ២.៤៣៨,៧៤ | ១.៩០០,០០ |
| សរុប II | | ២៧.៣១០,៩៤ | ២៧.៣២៤,៤០ | ១៨.៥៥៨,៨៣ | ១០.០៩២,៦៤ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៨៤.៩០២,០០ | ២៧.៥៦៣.០០ | ២៧.៥៦៣.០០ |
| សរុប III | | ៦១.២៧១,០០ | ២២០.៣៤៨,០០ | ២៧.៥៦៣,០០ | ២៧.៥៦៣,០០ |
| សរុប I+II+III | | ៨៨.៩៨៨,៥៤ | ២៤៨.០១៦,៧១ | ៤៦.៣៨៤,០៣ | ៣៧.៧៥៥,៦៤ |

### ២.២ ការងារស្រាវជ្រាវកៅស៊ូកម្ពុជា ការផ្សព្វផ្សាយ បណ្តុះបណ្តាល និងសកម្មភាពផ្សេងៗទៀត

-ចុះត្រួតពិនិត្យការប្រមូលទឹកជ័រតាមចម្ការពិសោធន៍នីមួយៗ

-ចុះត្រួតពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានក្រុមហ៊ុន ស៊ីហ្សីសសស៍ លីមីតធីត និងចម្ការកៅស៊ូស្នួល

-បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសមាសភាពចង្រៃនិងជំងឺកៅស៊ូដែលមានអ្នកចូលរួមចំនួន៥០នាក់ មកពីខេត្តត្បូងឃ្មុំ ក្រចេះ សៀមរាប កំពង់ស្ពឺ ស្វាយរៀង និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលកវិទ្យាល័យស្វាយរៀង

-ចូលរួមជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ NAGOYA (ជប៉ុន) ដើម្បីត្រួតពិនិត្យនិងជួសជុលឧបករណ៍ Sapflow, Co2 profile និងតាមដានទិន្នន័យ Stemflow និង Trow fall

-ចុះយកសំណាកស្លឹកកៅស៊ូនៅស្រុកសន្ទុក សណ្តាន់ ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ និងស្រុករវៀង ខេត្តព្រះវិហារ និងស្រុកបន្ទាយស្រី ខេត្តសៀមរាប ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និងខេត្តប៉ៃលិន សរុបបានចំនួន៤៩៣សំណាកពីច្បារពូជកសិករចំនួន២០ ដើម្បីវិភាគ DNA ក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជនៅកម្ពុជា។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣៩៣ក្បាល ក្នុងនោះជ្រូកបាចំនួន១៣ក្បាល ជ្រូកមេចំនួន១០២ក្បាល និងកូនជ្រូកចំនួន១៨៥ក្បាល

-គោសរុបចំនួន២០១ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥១ក្បាល គោបៅដោះចំនួន៤៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺអុតក្តាមចំនួន១.៦០០ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន១.១១៩ក្បាល ជំងឺប៉េស្តចំនួន៣.៩៦៧ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន២.៨៨២ក្បាល ជំងឺអូហ្យេស្គីចំនួន១៩៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៥.២៤៥ក្បាល ជំងឺញីវកាសចំនួន១១.៣០៣ក្បាល ជំងឺអាសន្នរោគចំនួន៨.៦៩៧ក្បាល និងជំងឺប៉េស្តទាចំនួន១.០០០ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន១២៣សំណាក

-បានពិនិត្យវត្ថុវិភាគសរុបចំនួន៣ក្បាល។

### ៣.៤ ការងារអភិវឌ្ឍឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន១៦១ឡ។

### ៣.៥ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន៥ករណី មកពីតាមបណ្ដារាជធានី ខេត្តចំនួន៤ សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្ដាសាយបក្សី

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្ដាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងជ្រូកចំនួន១២លើក មាន់ចំនួន២២លើក ទាចំនួន១១លើក ទ្រុងចិញ្ចឹមចំនួន២លើក បរិវេណភូមិចំនួន៥៨លើក និងសត្តឃាតដ្ឋានចំនួន៣៩លើក

-ចាត់ក្រុមអន្តរាគមន៍ចុះប្រតិបត្តិការជាប្រចាំដើម្បីធ្វើការទប់ស្កាត់ចលនាបក្សី និងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ ដោយបានអនុវត្តវិធានការបសុពេទ្យជាក់ស្ដែង ព្រមទាំងបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្ដាលមកពីជំងឺផ្ដាសាយបក្សី។ ក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសអាជីវកម្មចលនាសត្វ និងផលិតផលសត្វសហការជាមួយការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី-ខេត្ត បានបង្ក្រាបបទល្មើសដឹកជញ្ជូនស៊ុតទាខុសច្បាប់០១ករណី បានធ្វើការត្រួតពិនិត្យការដឹកជញ្ជូនគោ-ក្របី០៣ករណី ជ្រូក០៨ករណី សាច់មាន់០១ករណី និងស៊ុតទា០២ករណី។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ៧.៤១៥,៦៣៧ម៣ ឈើជ្រុងចំនួន៦.៥៦៤,៣៨៨ម៣ កូនឈើចំនួន១០១.៣១៣ដើម និងអុសចម្រុះចំនួន៦២.៥៩៧ស្ទែរ

-ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៣សហគមន៍ ដែលមានផ្ទៃដី២.៤០៣ហិកតា ស្ថិតក្នុងខេត្តកំពង់ស្ពឺ

-សហគមន៍ព្រៃឈើនៅទូទាំងប្រទេសមានចំនួន៤៧៩សហគមន៍ ដែលអង្គភាពជំនាញកំពុងខិតខំពង្រឹងសហគមន៍ទាំងនោះតាមរយៈការទាក់ទាញជំនួយបច្ចេកទេសពីដៃគូដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ឲ្យអនុវត្តការធ្វើកសិកម្មចម្រុះបន្ថែមទៀត ដោយមិនអាស្រ័យទៅលើតែផល អនុផលព្រៃឈើ ព្រមទាំងចូលរួមថែរក្សា ការពារព្រៃឈើនៅក្នុងសហគមន៍ប្រកបដោយនិរន្តរភាព។

### ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួន៤៧ប្រភេទ ប្រមាណ៣៤.០០០ក្បាល

-ចុះស្រាវជ្រាវសត្វព្រៃនៅក្នុងព្រៃការពារព្រះវិហារចំនួន០២លើក និងព្រៃការពារមណ្ឌលគិរីចំនួន០២លើក ដោយរកឃើញសត្វព្រៃសំខាន់ៗដូចជា ដំរី ខ្ទីង ទន្សោង ប្រើស ត្រយ៉ងយក្ស ត្នាត ត្រដក់តូច ឈ្លូស ប្រើស និងក្ងោក មាន់ព្រៃ ត្រកួត និងអណ្ដើក

-រៀបចំអាហារដ្ឋានត្មាតចំនួន០២លើក នៅតំបន់អភិរក្សជីវចម្រុះសៀមប៉ាងនិងព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបប្រមាណជិត២០០ក្បាល

-ការពារសម្បុកសត្វត្រយ៉ងចង្កំ ស ចំនួន៣៧ក្បាល ត្មាតចំនួន១២ក្បាល ត្រយ៉ងយក្សចំនួន៣ក្បាល និងក្រៀលចំនួន១២ក្បាល នៅតំបន់សៀមប៉ាងភាគខាងលិច និងតំបន់ព្រះវិហារ។

### ៤.៣ ការងារអប់រំផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន៣៥លើក ស្ដីពីការរៀបចំគ្រប់គ្រងអភិរក្សសត្វខ្សឹប មូលនិធិអភិវឌ្ឍន៍សហគមន៍ និងអភិរក្សសត្វស្លាប និងទប់ស្កាត់ការកាប់រានដីព្រៃ ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន១.០២១នាក់ ស្ត្រី៤៨៤នាក់។

### ៤.៤ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជសា្វក្តាម និងការសង្គ្រោះសត្វព្រៃ

-ក្នុងខែកក្កដា ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៣៣ក្បាល សត្វកើតថ្មីចំនួន២ក្បាល សត្វដោះលែងចំនួន១១ក្បាល សត្វស្លាប់ចំនួន៩ក្បាល ព្យាបាលសត្វចំនួន២៧ក្បាល យកសំណាកទៅពិសោធន៍ចំនួន១០ក្បាល ធ្វើឲ្យសន្លប់ចំនួន២៥ក្បាល ទម្លាក់សត្វល្អិតចំនួន១១ក្បាល វះកាត់សាកសពសត្វចំនួន៦ក្បាល ដាក់លេខកូដចំនួន៤ក្បាល ចាក់វ៉ាក់សាំងចំនួន២០៦ក្បាល

ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន១៧ម² ជួសជុលផ្លូវចំនួន១៨.៦៥០ម² សាងសង់សំណង់ផ្សេងៗចំនួន៥៤ម² ថ្លារអនាម័យព្រៃចំនួន១២.៣២០ម² ដាំកូនឈើចំនួន២២៩ដើម បណ្តុះផ្កាលម្អចំនួន២.៨៨០ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១.២៣១នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមសត្វក្ដាមមេ-បាពូជ និងកូនសត្វក្ដាមចំនួន៥៥.៣០៩ក្បាល។

**៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ**

-បន្តថែរក្សាកូនក្រពើចំនួន២២ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង។

**៤.៦ ការងារដាំដើមឈើ**

-ការដាំឈើក្នុងពិធីបុណ្យភ្ជុំទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីព្រៃសរុបចំនួន១២៥ហិកតា និងដាំឈើជាចម្ការបានចំនួន១៨០ហិកតា។

**៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០២ ដែលមានបរិមាណឈើសរុបចំនួន៣.៦៨០,៥០០ម³

-ផ្តល់អាជ្ញាប័ណ្ណនាំចូលឈើកែច្នៃជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើសរុបចំនួន១.៣០០ម³

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង៨១សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន១៤.៣៧៩,៧៥៦ម³

-ផ្តល់គោលការណ៍ឲ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៣កន្លែង និងពន្សារសុពលភាពចំនួន២កន្លែង ព្រមទាំងបានផ្តល់គំរូលិខិតបង្កើតរោងសិប្បកម្មធុនតូចចំនួន២០សន្លឹក និងរោងសន្និធិចំនួន២០សន្លឹក។

**៤.៨ ការងារចំណូលព្រៃឈើ**

-ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១.៤៣០.១៤៥.០៨៥រៀល និងផ្តល់សេវាសាធារណៈចំនួន៣៥.៩៧៤,៤១ដុល្លារ និង៨៧៨.០១៤.៥៧៦រៀល។

**៤.៩ ការងារនីតិកម្មនិងវិវាទ**

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសសរុបចំនួន២២៥ករណី ដោយបញ្ជូនទៅតុលាការសរុបចំនួន១៤២ករណី និងពិន័យអន្តរការណ៍ចំនួន៨៣ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៤៣៧ម³ ឈើអារចំនួន៧២៣ម³ ឈើក្រាក់គ្រញូងចំនួន៨ម³និង៣១៧គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដកហូតដីព្រៃឈើចំនួន២២២ហិកតា

-ស្ថិតិដីព្រៃទទួលរងការកាប់រានសរុបចំនួន១.៣៧៧ហិកតា និងបានបង្ក្រាបការកាប់រានដីព្រៃឈើសរុបចំនួន៤១៩ហិកតា

-បង្ក្រាបនិងដកហូតរណារយន្តកាត់-អារឈើសរុបចំនួន៣៨គ្រឿង។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន២៤.០០០តោន ស្មើ១៦០% នៃផែនការ

១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១១.០០០តោន(បញ្ចប់រដូវ)

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១០.០០០តោន សរុបបានចំនួន១៩០.០០០តោន ស្មើ៤៨,៧២% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤៥.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១០.០០០តោន សរុបបានចំនួន៦៥.០០០តោន ស្មើ៣៦,១១% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន។

**៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤**

-អនុវត្តក្នុងខែចំនួន៨.០០០តោន សរុបចំនួន៦១.០០០តោន ស្មើ៥៧,២៧% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន។

**៥.២ វារីវប្បកម្ម**

-ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន៥៧.០០០តោន ស្មើ៥៧% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០តោន

-ការចិញ្ចឹមក្រពើ ក្នុងខែចំនួន២០.០០០ក្បាល សរុបបានចំនួន១៩០.០០០ក្បាល ស្មើ៦៣,៣៣% នៃផែនការ ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួន៤០.០០០.០០០កូន សរុបបានចំនួន១២០.០០០.០០០កូន ស្មើ៦៦,៦៧% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០.០០០.០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន៤២.០០០ តោន ស្មើ២៨% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ ក្នុងខែចំនួន៣០០តោន សរុបបានចំនួន៥.៨០០តោន ស្មើ៧២,៥០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨០០តោន

-ការផលិតទឹកត្រី ក្នុងខែចំនួន៣.០០០.០០០លីត្រ សរុបបានចំនួន៤៨.០០០.០០០លីត្រ ស្មើ៨០% នៃផែនការ ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨.០០០.០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន៦.៥០០តោន ស្មើ៣២,៥០% នៃផែនការ២០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០០តោន

-ផលនេសាទកែច្នៃ ក្នុងខែចំនួន៥០០តោន សរុបបានចំនួន៣.៣០០តោន ស្មើ៣៣% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន។

**៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

-កំណត់ហេតុបទល្មើស សរុបចំនួន១.១៤៥ករណី ដែលកើតមាននៅតំបន់ទឹកសាប១.១០០ករណី និងតំបន់សមុទ្រ ៤៥ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤០៥ករណី គឺតំបន់ទឹកសាបថយចុះ៤០០ករណីនិងតំបន់សមុទ្រថយចុះ៥ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

**៥.៦ ការប្រមូលចំណូល**

-ចំណូលពីវិស័យជលផល ក្នុងខែចំនួន១៣៩.៥៥៩.៤៣៨រៀល សរុបបានចំនួន២.០៩៦.១៥៣.០៣២រៀល ស្មើ៦៨,៩០% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥៥៩.១៦៨.៤៤១ រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-បើកវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធព័ត៌មានវិទ្យា ដែលមានមន្ត្រី និងនិយោជិតចូលរួមសរុបចំនួន២៣នាក់

-ចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលាស្តីពីការនាំអង្ករចេញរបស់កម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី

-ចុះត្រួតពិនិត្យវាយតម្លៃការងារពិសោធន៍ស្រាវជ្រាវ នៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ

-ចុះត្រួតពិនិត្យជ្រើសរើសទីកន្លែងពិសោធន៍ និងចែកសម្ភារៈពិសោធន៍ដល់អ្នកសហការ នៅខេត្តបាត់ដំបង កំពង់ឆ្នាំង និងខេត្តតាកែវ

-ចុះត្រួតពិនិត្យនិងតាមដានដំណើរការនៃការរៀបចំស្រែបង្ហាញ និងការងារផ្សព្វផ្សាយពូជស្រូវ នៅខេត្តកែប និងខេត្តព្រះសីហនុ

-ចុះផ្ទៀងផ្ទាត់ព័ត៌មាន និងធ្វើការអង្កេតស្តីពីខ្សែសង្វាក់ផលិតកម្មដំណាំស្វាយជាមួយអ្នកប្រមូលទិញ នៅខេត្តបាត់ដំបង

-ចុះប្រមូលព័ត៌មានស្តីពីការដាំដុះដំណាំដំឡូងផ្ទានិងដំណាំស្រូវក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនៅខេត្តកំពង់ស្ពឺ និងខេត្តកំពត

-ចុះអនុវត្តបង្ហាញនូវការប្រើប្រាស់ម៉ាស៊ីនដាំគ្រាប់ស្រូវស្ងួតដែលអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា នៅខេត្តកំពង់ចាម និងខេត្តព្រៃវែង។

## ៧ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤៨៥ច្បាប់ សរុបចំនួន៣.២៩៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៤៣១ច្បាប់ សរុបចំនួន២.៤៩៩ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១២៤ច្បាប់ សរុបចំនួន៧៩២ ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៧១៩ច្បាប់ សរុបចំនួន៥.០៥០ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣០ច្បាប់ សរុបចំនួន៣៤២ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៨ច្បាប់ សរុបចំនួន៤៥៧ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

-បានរៀបចំសេចក្តីព្រាងស្តីពីការបង្កើតអង្គភាពថវិកា (BE)

-រៀបចំបូកសរុបកញ្ចប់ថវិកាសម្រាប់ឆ្នាំ២០១៥ និងចូលរួមប្រជុំការពារថវិកា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចធ្វើការកែសម្រួលលើការគ្រោងកញ្ចប់ថវិកាឆ្នាំ២០១៥ឡើងវិញក្រោយពីមានការណែនាំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ចូលរួមប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិនិត្យពិភាក្សាឡើងវិញលើការរៀបចំMAP 2-NEW នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ប្រជុំពិភាក្សាកែសម្រួល MAP 2-NEW របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៦នាក់ នារីចំនួន១.២៧៧នាក់ ស្មើនឹង១៩% ក្នុងនោះៈ

-អង្គភាពថ្នាក់កណ្តាលចំនួន៤.០៨៤នាក់ ក្នុងនោះនារីចំនួន៧៤៥នាក់ ស្មើនឹង១៨,២៤%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦០២នាក់ ក្នុងនោះនារីចំនួន៥៣២នាក់ ស្មើនឹង២០,៤៤%

-ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន៩នាក់ ក្នុងនោះបោះបង់ការងារចំនួន២នាក់ សុំលាឈប់ពីការងារចំនួន១នាក់ និងមរណភាពចំនួន៦នាក់

-ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៣នាក់

-ថ្នាក់ដឹកនាំមន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៩នាក់

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-ចូលរួមប្រជុំពិភាក្សាលើផែនការសកម្មភាពនិងតម្រូវការហិរញ្ញវត្ថុសម្រាប់ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុឆ្នាំ២០១៤-២០១៨

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញគ្រប់គ្រងស្ថាប័នប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងទំនាស់និងដំណោះស្រាយ និងការគ្រប់គ្រងប្រសិទ្ធភាពការងារ

-ចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីសុខុដុមនីយកម្មលើការគាំពារសង្គម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងបរិបទអាស៊ាន

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីគាំទ្រការបន្តសុពលភាពកិច្ចព្រមព្រៀង AFoCo ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន-កូរ៉េក្នុងវិស័យព្រៃឈើ

-ចូលរួមតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពនៃឧទ្យានគំរូមិត្តភាពវិទ្យាសាស្ត្រ និងបច្ចេកទេសកសិកម្មក្នុងក្របខ័ណ្ឌនៃគម្រោងសហប្រតិបត្តិការទ្វេភាគីរវាងមន្ទីរកសិកម្មខេត្តយូណាន់ នៃសាធារណរដ្ឋប្រជាមានិតចិន និងមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ

-បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៥២នាក់ នៅក្នុងប្រទេសចំនួន១៣

-សម្របសម្រួលចុះហត្ថលេខាលើឯកសារស្តីពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាមិត្តនិងដៃគូអភិវឌ្ឍន៍ដូចជា សេចក្តីព្រាង MOU ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មរវាងកម្ពុជា-បង់ក្លាដេស និងកិច្ចព្រមព្រៀងជាមួយអង្គការអន្តរជាតិនៅកម្ពុជាសហការក្នុងវិស័យកសិកម្ម។

## ១១ ការខារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១១.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥១១នាក់(ស្រី៤៩៣នាក់) ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សាលាជាតិកសិកម្មព្រែកលៀបកំពុងជំរុញគ្រប់ដេប៉ាតឺម៉ង់ និងផ្នែកសិក្សាបន្តឲ្យពិនិត្យនិងកែតម្រូវសារណារបស់និស្សិតឲ្យបានលឿនសម្រាប់ពិធីការពារសារណានៅពេលខាងមុខ ព្រមទាំងរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីបញ្ហាប្រឈមក្នុងការគ្រប់គ្រងស្រូវ អង្ករនៅក្រោយពេលប្រមូលផលដល់និស្សិតដែលកំពុងសិក្សាចំនួន១៧០នាក់ផងដែរ។ សាលាជាតិកសិកម្មព្រែកលៀបក៏បានចាត់តំណាងចូលរួមសិក្ខាសាលាស្តីពីការអនុវត្តកសិកម្មល្អ នៅសណ្ឋាគារសាន់វេ និងសិក្ខាសាលាស្តីពីភាពចាំបាច់នៃការប្រើប្រាស់និងការថែទាំឧបករណ៍បូមទឹកនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

### ១១.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១១.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់ (ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។ មន្ត្រីសាស្ត្រាចារ្យទាំងក្នុងនិងក្រៅបានខិតខំយកចិត្តទុកដាក់ធ្វើការអភិវឌ្ឍនូវមុខជំនាញបច្ចេកទេសរបស់ខ្លួន ពិសេសអភិវឌ្ឍសម្ភារបច្ចេកទេសបង្រៀនឲ្យកាន់តែប្រសើរឡើង និងធ្វើការសិក្សាស្រាវជ្រាវសំដៅលើកកម្ពស់គុណភាពសិក្សា និងចូលរួមគ្រប់សកម្មភាពទាំងការងាររៀននិងបង្រៀន។ ចូលរួមដឹកនាំនិស្សិតចុះធ្វើកម្មសិក្សានៅតាមរាជធានី ខេត្ត និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ធ្វើបទបង្ហាញនានាទាំងក្នុងនិងក្រៅប្រទេស និងទៅជួយបង្រៀនដល់នាយទាហានសកម្មនៃកងយុទ្ធពលខេមរភូមិន្ទនៅសាលាត្បាតពង និងនិស្សិតនាយទាហាននៅវិទ្យាស្ថានកងទ័ពជើងគោក(គីរីរម្យ) ព្រមទាំងបន្តអនុវត្តគម្រោងស្រាវជ្រាវចំនួន២២គម្រោង លើផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដី និងរដ្ឋបាលដីធ្លី និងធ្វើការផ្លាស់ប្តូរបទពិសោធន៍រវាងសាស្ត្រាចារ្យ និងនិស្សិតពីគ្នាទៅវិញទៅមក។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមនិងតិចតួចគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន ៦២,១៣ភាគរយ នៃផែនការនិងមានសភាពលឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា ក្នុងនោះខេត្តអនុវត្តបានលឿនជាងគេគឺខេត្តបន្ទាយមានជ័យសម្រេចបាន៩៨,២៦ភាគរយនៃផែនការ។ ទន្ទឹមនឹងនោះ ប្រជាកសិករកំពុងបន្តយ៉ាងសកម្មក្នុងការងារបង្កបង្កើនផលដំណាំរដូវវស្សា ជាពិសេសខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដក ស្ទូង ដើម្បីឲ្យទាន់រដូវការដាំដុះ។ រីឯការប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៤កំពុងប្រព្រឹត្តទៅយ៉ាងមមាញឹក។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការត្រូវតែខិតខំបន្តសកម្មភាពដូចភ្លៀងរលឹម ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។ កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិកាន់តែទូលំទូលាយទទួលបាននូវជំនួយឥតសំណងជាច្រើនសម្រាប់កិច្ចការងារអភិរក្សនិងអភិវឌ្ឍព្រៃឈើ និងទទួលបាននូវការចាប់អារម្មណ៍កាន់តែខ្លាំងពីអន្តរជាតិលើការអនុវត្តកម្មវិធីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយសារការបាត់បង់និងរិចរិលព្រៃឈើ REDD+ ព្រមទាំងមានកិច្ចសហការកាន់តែជិតស្និទ្ធពីស្ថាប័នអយ្យការ តុលាការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធក្នុងការងារពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងជលផល។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការងារសវនកម្មផ្ទៃក្នុង ការងារអធិការកិច្ចនៅតាមបណ្តាអង្គភាពក្រោមឱវាទក៏ដូចជាមន្ទីរកសិកម្មរាជធានី ខេត្ត និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗ បានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## V- ទិសដៅអនុវត្តបន្ត

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំផ្សេងៗ។ល។

-បន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ឲ្យចុះជាប្រចាំ ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាលសង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្លាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម

-ទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីតាំងរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-ទំនាក់ទំនងនិងសហការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីទទួលបានជំនាញការមកជួយរៀបចំយន្តការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-ត្រៀមរៀបចំប្រជុំពិនិត្យពិភាក្សាលើការកែសម្រួល CAP 2-NEW, GDAP 2-New និង MAP 2-New របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀត និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង។ ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**